# គោលលទ្ធិស្ដីអំពីប្រវត្តិព្រះគម្ពីរ

## រឿងព្រះគម្ពីរសញ្ញាចាស់
(ពីសាំយ៉ូអែលរហូតដល់ការនិរទេស)

ថ្នាក់ដំបូង (កំរិត ១)
ភាគ ២

រៀបរៀងដោយ លោកគ្រូគង្វាល ស៊ី. ហានកូ
កែសំរួលដោយ ជេ. ជេ. លិម
ដោយមានការជួយឧបត្ថម្ភពីលោក ដាវីឌ ហ៊ីហ្គស៍
បោះពុម្ពខែ មករា ឆ្នាំ ២០១១

Copyright © Gratia Dei Sola Media

# អារម្ភកថាអ្នកនិពន្ធ

នេះគឺជាសៀវភៅក្បាលទី២ (ថ្នាក់ដំបូង កំរិត១ ភាគ២) ដែលមានទាំងអស់៣ក្បាល។ សៀវភៅនេះសរសេរអំពីប្រវត្តិសាស្រ្តនៃព្រះគម្ពីរត្រូវបានសរសេរជាទំរង់រឿងព្រះគម្ពីរ សម្រាប់អោយប្អូនៗមានអាយុពី៦ឆ្នាំដល់អាយុ៨ឆ្នាំ។ សៀវភៅភាគ២នេះបង្រៀនអំពីប្រវត្តិសាស្រ្ត ពីការចាប់ផ្ដើមរាជ្យស្ដេចសូលរហូតដល់ការត្រលប់ពីការនិរទេសវិញ។

មេរៀននីមួយៗ មានសម័យកាលនៃប្រវត្តិស្រាស្រ្តជាក់លាក់ និងមានដំណើររឿងទាក់ទងគ្នាពីចំនុចមួយទៅចំណុចមួយទៀតយ៉ាងច្បាស់លាស់។ ដូច្នេះគ្រូបង្រៀនអាចសម្រេចចិត្តបានយ៉ាងល្អក្នុងការប្រើប្រាស់សម្ភារៈនៅក្នុងថ្នាក់រៀន ដោយឆ្លងកាត់ការពិភាក្សាដ៏សមស្របមួយ។ ប៉ុន្តែប្អូនៗជាសិស្សត្រូវតែធ្វើការពិចារណាក្នុងចិត្ត និងយកចិត្តទុកដាក់ ដូច្នេះប្អូនៗជាសិស្សនឹងអាចយល់នូវរឿងរ៉ាវប្រវត្តិសាស្រ្តច្បាស់ជាមិនខាន។

សូមអោយព្រះវរបិតានៃស្ថានសួគ៌ ប្រទានពរដល់ពូជពង្សរបស់ ទ្រង់តាមរយៈការទាំងនេះផង ដើម្បីអោយសេចក្តីពិតនៃព្រះបន្ទូលរបស់ទ្រង់ អាចរក្សាទុកក្នុងចិត្តរបស់ប្អូនៗទាំងអស់គ្នា។ ហើយសូមអោយបានបន្ត ដល់ពួកអ្នកជំនាន់ក្រោយដែលនឹងមកដោយនូវ សិរីល្អនៃព្រះនាមទ្រង់។

**លោកគ្រូគង្វាល ស៊ី. ហានក្វូ**

Copyright © Gratia Dei Sola Media

# អារម្ភកថាអ្នកកែសម្រួល

ការប្រើប្រាស់សៀវភៅគោលជំនឿ សម្រាប់បង្រៀនប្អូនៗក្មេងៗនៅក្នុងព្រះវិហារ គឺជាវិធីសាស្ត្រពិសោធន៍ពេលវេលា និងជាវិធីបុរាណ។ សៀវភៅគោលជំនឿស្តីពីប្រវត្តិសាស្ត្រនេះ ត្រូវបានរៀបចំឡើង ដោយពួកជំនុំកំណែទម្រង់ប្រូតេស្តង់ (ទោះជាប្រើឈ្មោះផ្សេងៗ)។ គោលបំណងនៃសៀវភៅនេះ គឺផ្តល់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំដល់ប្អូនក្មេងៗអំពីប្រវត្តិសាស្ត្រ និងសេចក្តីពិតនៃព្រះគម្ពីរ។

បើសិនជាកូនរបស់លោក អ្នកមានសម្ថភាពអាចចងចាំបានច្រើនជាងអ្វីដែលយើងបានដាក់អោយធ្វើ (១០សំណួរ និង១០ខគម្ពីរចងចាំ)។ សៀវភៅនេះនឹងត្រូវយកមកបង្រៀនបន្ទាប់ពីបញ្ចប់សៀវភៅគោលលទ្ធិប្រវត្តិសាស្ត្រព្រះគម្ពីរ ទាំងពក្យាលកំរិត១។

សៀវភៅលំហាត់សម្រាប់សៀវភៅនេះ ក៏បានបោះពុម្ពចេញដែរ។ ឪពុកម្តាយត្រូវបានលើកទឹកចិត្តអោយជួយដល់កូនៗធ្វើលំហាត់ក្នុងពេលសមស្របការនេះ អាចជួយបន្ថែមលើការទន្ទេញចម្លើយសម្រាប់សំនួរចំនួនដប់សម្រាប់សប្តាហ៍នីមួយៗ។ ហើយតួនាទីរបស់គ្រូបង្រៀននៅសាលា Sabbath school គឺត្រូវបានរៀបចំបន្ថែមលើឪពុកម្តាយ(ជាពិសេសឪពុក) ដើម្បីជួយពន្យល់មេរៀនដល់កូនៗរបស់ពួកគាត់ ដោយប្រើវិធីត្រឹមត្រូវណាមួយមុនពេលពួកគេមកចូលថ្នាក់រៀន។ នៅក្នុងថ្នាក់គ្រូបង្រៀនអាចផ្តល់មេរៀនអោយអនុវត្តន៍ តែពីរឬបីប៉ុណ្ណោះ

Copyright © Gratia Dei Sola Media

បន្ទាប់មកទើបធ្វើការរំលឹកមេរៀនជាមួយសិស្សម្នាក់ៗ ដោយសាកល្បងសួរសំនួរគេទាំងអស់គ្នា នូវមេរៀនចងចាំរបស់ពួកគេរៀងៗខ្លួន។

សូមអោយព្រះអម្ចាស់ ប្រទានពរដល់ការខិតខំប្រឹងប្រែងរបស់យើងរាល់គ្នាក្នុងការជួយបង្រៀនកូនៗយើង អោយដើរក្នុងផ្លូវនៃព្រះអម្ចាស់។

**លោកគ្រូគង្វាល ជេ. ជេ. លិម**

Copyright © Gratia Dei Sola Media

**Bible History Catechism-Old Testament Bible Stories**
**(From Saul to the Return from Captivity)**
**Beginners- Book 2/3**

By Rev C. Hanko edited by PsK.J.Lim
With invaluable contributions by Ps David Higgs

Original version by Rev C.Hanko are property of the Protestant Reformed Churches of America

J.J.Lim edited version ©2011 by Pilgrim Covenant Church.

Khmer Language version © Gratia Dei Sola Media

Published by Gratia Dei Sola Media

Blk 203B, Henderson Road, #07-07, Singapore 159546.
Website: www.gdsmedia.org
Email:gdsmedia.sg@gmail.com

All rights reserved Printed in Singapore

Copyright © Gratia Dei Sola Media

# មេរៀនទី ១

# ស្តេចសូល

## ១សាំយូអែល ៨-១៥, ២៨, ៣១

**១. ហេតុអ្វីបានជាពួកសាសន៍អ៊ីស្រាអែលចង់បានស្តេចមួយអង្គ?**
ពួកគេចង់បានអោយដូចជាសាសន៍ដ៏ទៃទៀត។
(១សាំយូអែល៨:៤-៥)

**២. តើព្រះយេហូវ៉ាបានផ្តល់ស្តេចអោយពួកគេមួយអង្គទេ?**
មែនហើយ ទ្រង់បានអោយស្តេចសូលទៅពួកគេ ដែលជាកុលសម្ព័ន្ធបេនយ៉ាមីន។ (១សាំយូអែល៩:១៦-១៧,១០:១)

**៣. តើសូលគឺជាស្តេចល្អមួយអង្គឬ?**
ទេ! គាត់ជាស្តេចដ៏អាក្រក់មួយអង្គ ។
(១សាំយូអែល១៥:១០-១១)

**៤. តើសូលបានបង្ហាញថាគាត់ជាមនុស្សអាក្រក់យ៉ាងដូចម្តេច?**
គាត់មិនបានស្តាប់តាមបញ្ញត្តិរបស់ព្រះយេហូវ៉ាទេ។
(១សាំយូ អែល១៣ :៧-១៤,១៥:១-៩)

**៥. តើព្រះយេហូវ៉ាបានធ្វើទោសដល់សូលដូចម្តេច?**
ព្រះទ្រង់បានដកយកនគរនោះចេញពីសូល។
(១សាំយូអែល១៥:២២-៣០)



Copyright © Gratia Dei Sola Media

**៦. តើព្រះយេហូវ៉ាមានបន្ទូលទៅកាន់សូលទៀតទេ បន្ទាប់ពីពេលនោះ?**

ទេ!ទ្រង់មិនបានមានបន្ទូលទៅកាន់គាត់ទៀតទេ។

(១សាំយូអែល ២៨:៦,១៥)

**៧. តើសូលមានចំណាងចង់ស្វែងរកជំនួយពីព្រះយេហូវ៉ាឬទេ?**

ប្រាកដណាស់ មុនសង្គ្រាមជាមួយពួកសាសន៍ភីលីស្ទីន។

(១សាំយូអែល២៨:៣-៦)

**៨. តើសូលបានទៅណា ចាប់ពីពេលដែលព្រះយេហូវ៉ាមិនមានបន្ទូលទៅឯគាត់?**

គាត់បានទៅឯគ្រូអាបធ្មប់ម្នាក់នៅពេលយប់។

(១សាំយូអែល២៨:៧-៨)

**៩. តើសូលបានទទួលសារអ្វី?**

សារនោះប្រាប់ថា គាត់នឹងត្រូវស្លាប់ ។

(១សាំយូអែល២៨:១៩-២០)

**១០.តើសូលបានស្លាប់យ៉ាងដូចម្តេច ?**

គាត់បានសម្លាប់ខ្លួនឯងនៅក្នុងសង្គ្រាម។

(១សាំយូអែល៣១:១-៥)

**ខគម្ពីរចងចាំ៖** "ដ្បិតព្រះយេហូវ៉ា ទ្រង់ជ្រាបផ្លូវរបស់មនុស្សសុចរិត តែផ្លូវរបស់មនុស្សអាក្រក់នឹងវិនាសវិញ"។ (ទំនុកដំកើង ១:៦)



Copyright © Gratia Dei Sola Media

# មេរៀនទី ២
# ដាវីឌត្រូវបានចាក់ប្រេងតាំងជាស្តេច
# ១សាំយូអែល ១៦-២៨

**១. តើសាំយូអែលបានចាក់ប្រេងតាំងអោយអ្នកណា នៅក្នុងកន្លែងរបស់សូល?**
ដាវីឌ ដែលចេញពីពូជអំបូរយូដា។(១សាំយូអែល១៦:១១-១៣)

**២. តើដាវីឌបានធ្វើអ្វីកាលពីគាត់នៅជាក្មេងប្រុសនៅឡើយ?**
គាត់បានជួយថែហ្វូងចៀមរបស់ឪពុករបស់គាត់។
(១សាំយូអែល១៦:១១,១៩,១៧:១៥,២០)

**៣. តើព្រះយេហូវ៉ាបានគង់នៅជាមួយគាត់ទេ ពេលគាត់នៅក្មេង?**
ពិតណាស់ ព្រះយេហូវ៉ាបានសង្គ្រោះគាត់ចេញពីសត្វតោ និងខ្លាឃ្មុំ។(១សាំយូអែល១៧:៣៤-៣៧)

**៤. តើអ្នកណាបានសើចចំអកអោយពួកទ័ពអ៊ីស្រាអែល?**
មនុស្សមាឌធំ កូលីយ៉ាត។ (១សាំយូអែល១៧:៤,៨-១០,២៦)

**៥. តើដាវីឌបានធ្វើអ្វីទៅលើកូលីយ៉ាត?**
គាត់បានសម្លាប់កូលីយ៉ាតដោយប្រើចំពាមកៅស៊ូ ។
(១សាំយូអែល១៧:៤៧-៥០)


Copyright © Gratia Dei Sola Media

**៦. តើសូលសប្បាយចិត្តទេ ពេលដឹងថាដាវីឌសម្លាប់កូលីយ៉ាត?**
ទេ! គាត់មានចិត្តច្រណែននឹងដាវីឌ។ (១សាំយូអែល១៨:៧-៩)

**៧. ហេតុអ្វីបានជាគាត់មានចិត្តច្រណែននឹងដាវីឌ?**
ព្រោះគាត់ដឹងថា ព្រះយេហូវ៉ានឹងអោយដាវីឌធ្វើជាស្តេច។
(១សាំយូអែល១៦:១-៤, ២០:៣១)

**៨. តើសូលបានព្យាយាមសម្លាប់ដាវីឌដូចម្តេច?**
គាត់បានដេញតាមចាប់ដាវីឌ ជាមួយនឹងទ័ពរបស់គាត់។
(១សាំយូអែល២៣:៧-៨)

**៩. តើដាវីឌបានលាក់ខ្លួននៅឯណា?**
គាត់បានលាក់ខ្លួននៅក្នុងរអាងភ្នំ ។ (១សាំយូអែល២៤:១-៨)

**១០.តើសូលអាចសម្លាប់ដាវីឌបានឬទេ?**
ទេ! ព្រោះព្រះយេហូវ៉ាតែងតែជួយថែរក្សាគាត់រហូត។
(១សាំយូអែល ២៧:៤,២៨:១៦-១៧)

**ខគម្ពីរចងចាំ៖** "អើ ទោះបើទូលបង្គំដើរកាត់ច្រកភ្នំនៃសេចក្តីស្លាប់ក៏ដោយ ក៏គង់តែមិនខ្លាចសេចក្តីអាក្រក់ណាឡើយ ដ្បិតទ្រង់គង់នៅជាមួយនឹងទូលបង្គំ"។ (ទំនុកដំកើង ២៣:៤)


Copyright © Gratia Dei Sola Media

# មេរៀនទី ៣
# ស្តេចដាវីឌ
## ២សាំយូអែល ២-១២

**១. តើអ្នកណាបានក្លាយជាស្តេចបន្ទាប់ពីសូលបានស្លាប់?**
ដាវីឌ ដែលជាអ្នកដែលគោរពកោតខ្លាចដល់ព្រះយេហូវ៉ា។
(២សាំយូ អែល២:១-៤)

**២. តើស្តេចដាវីឌរស់នៅកន្លែងណា?**
នៅឯក្រុងយេរូសាឡិម ។ (២សាំយូអែល៥:៦-៧,៩)

**៣. តើស្តេចដាវីឌបាននាំយកអ្វីមកឯក្រុងយេរូសាឡិម?**
ហឹបនៃព្រះ ។ (២សាំយូអែល៦:១២,១៥-១៧)

**៤. តើស្តេចដាវីឌមានគំរោងសាងសង់អ្វីនៅក្នុងក្រុងយេរូសាឡិម?**
ព្រះវិហារដ៏ស្អាតមួយសំរាប់ព្រះ។
(២សាំយូអែល៧:១-៥,១ពង្សាវតាក្សត្រ៨:១៧)

**៥. តើស្តេចដាវីឌបានសង់វិហារនេះទេ?**
ទេ! ព្រោះព្រះបានប្រាប់គាត់ថា កូនរបស់គាត់សាឡូម៉ូននឹងសង់ជំនួសគាត់។
(២សាំយូអែល៧:១១-១៣,១ពង្សាវតាក្សត្រ ៨:១៨-១៩)


Copyright © Gratia Dei Sola Media

**៦. តើទង្វើអាក្រក់អ្វីទៅដែលជាបាបដ៏ធ្ងន់ធ្ងររបស់ស្តេចដាវីឌ?**
គាត់បានយកប្រពន្ធរបស់មនុស្សប្រុសម្នាក់។
(២សាំយូអែល១១:២-៥)

**៧. តើស្តេចដាវីឌព្យាយាមលាក់អំពើបាប ដែលគាត់យកប្រពន្ធគេ យ៉ាងដូចម្តេច?**
គាត់បានសម្លាប់ប្តីរបស់នាង ដោយដាក់គាត់នៅជួរមុខគេក្នុង សង្គ្រាម។ (២សាំយូអែល១១:១៤-១៧)

**៨. តើស្តេចដាវីឌមានការសោកស្តាយ ចំពោះអំពើបាបគាត់ទេ?**
មែន គឺពេលព្រះយេហូវ៉ា បញ្ជូនហោរាណាថាន់មកឯគាត់។
(២សាំយូអែល១២:១-១៣,ទំនុកដំកើង៣២,ទំនុកដំកើង៥១)

**៩. តើព្រះយេហូវ៉ាបានបង្ហាញដូចម្តេច ថាទ្រង់មិនសព្វព្រះទ័យជាមួយដាវីឌ?**
ទ្រង់បានធ្វើអោយកូនប្រុសរបស់ដាវីឌមានជំងឺជាខ្លាំង
ហើយក៏ ស្លាប់ទៅ។

**១០.តើព្រះយេហូវ៉ាបានដាក់ទោសដាវីឌតាមវិធីផ្សេងទៀតឬទេ?**
មែនហើយ ទ្រង់បានយកបញ្ហាជាច្រើន មកដាក់លើគ្រួសារ គាត់។ (២សាំយូអែល១២:១០-១២)

**ខគម្ពីរចងចាំ៖** "មានពរហើយ មនុស្សណាដែលការរំលងច្បាប់របស់ខ្លួន បានអត់ទោសអោយ គឺដែលបាបរបស់ខ្លួនបានគ្របបាំងហើយ"។
(ទំនុកដំកើង ៣២:១)


Copyright © Gratia Dei Sola Media

# មេរៀនទី ៤
# អំពើបាបរបស់អាប់សាឡំម
## ២សាំយូអែល ១៥-១៩

**១. តើអាប់សាឡំមជាអ្នកណា?**
ជាកូនរបស់ស្តេចដាវីឌ ។(២សាំយូអែល៣:២-៣)

**២. តើអាប់សាឡំមបានប្រព្រឹត្តបាបអ្វី?**
គាត់បានព្យាយាមដណ្តើមរាជ្យពីឪពុករបស់គាត់។
(២សាំយូអែល១៥:១-១២)

**៣. តើហេតុអ្វីបានជាអាប់សាឡំមធ្វើបែបនេះខុស?**
ព្រោះព្រះយេហូវ៉ាបានតែងតាំងដាវីឌអោយធ្វើជាស្តេច។
(២សាំយូអែល ៥:៣,១សាំយូអែល២៤:១០)

**៤. តើប្រជារាស្ត្រចង់អោយអាប់សាឡំធ្វើជាស្តេចឬទេ?**
មែនហើយ មានប្រជាជនជាច្រើនចូលចិត្តគាត់។
(២សាំយូអែល១៥:១៣)

**៥. តើស្តេចដាវីឌចង់ច្បាំងទាស់នឹងកូនរបស់គាត់អាប់សាឡំឬទេ?**
ទេ! គាត់បានភៀសខ្លួនចេញពីក្រុងយេរូសាឡិម។
(២សាំយូអែល១៥:១៤)


Copyright © Gratia Dei Sola Media

**៦. តើស្តេចដាវីឌបានភៀសខ្លួនតែម្នាក់ឯងឬ?**
ទេ! ទ័ពរបស់គាត់បានទៅជាមួយនឹងគាត់ដែរ ។
(២សាំយូអែល ១៥:១៥-១៨)

**៧. តើអាប់សាឡុំមបានតាមពីក្រោយដាវីឌឬទេ?**
ពិតមែនហើយ គាត់បានមកតាមទ័ពរបស់គាត់ដើម្បីច្បាំងនឹងដាវីឌ។ (២ សាំយូអែល១៧:១,២៤-២៦)។

**៨. តើមានអ្វីកើតឡើង ក្នុងចម្បាំងរវាងទ័ពរបស់ដាវីឌ និងទ័ពរបស់អាប់សាឡុំម?**
អាប់សាឡុំម ទ្រង់បានទាក់ព្រះសិរជាប់ទៅនឹងមែកឈើព្យួរផុតពីដី ។ (២សាំយូអែល១៨:៩-១០)

**៩. តើចម្បាំងនេះបានបញ្ចប់យ៉ាងដូចម្តេច?**
អាប់សាឡុំមត្រូវបានស្លាប់ ។ (២សាំយូអែល១៨១៤-១៧)

**១០.តើដាវីឌត្រឡប់ទៅក្រុងយេរូសាឡិមវិញទេ?**
មែនហើយ គាត់បានធ្វើជាស្តេចដូចពេលមុនវិញ។
(២សាំយូអែល១៩:១៤-១៥)

**ខគម្ពីរចងចាំ៖** "ព្រះទ្រង់ជាទីពឹងជ្រក ក៏ជាកំលាំងនៃយើងខ្ញុំ និងជាជំនួយដែលនៅជាប់ជាមួយក្នុងគ្រាអាសន្ន"។ (ទំនុកដំកើង ៤៦:១)


Copyright © Gratia Dei Sola Media

# មេរៀនទី ៥
# ស្ដេចសាឡូម៉ូន
## ១ពង្សាវតារក្សត្រ ១-១១

**១. តើអ្នកណាបានឡើងសោយរាជ្យបន្ទាប់ពីស្ដេចដាវីឌស្លាប់?**
សាឡូម៉ូនដូចដែលដាវីឌបានសន្យាទុក។
(១ពង្សាវតារក្សត្រ១:១៧,៣៤-៣៥,៣៩,២:១-២,១២)

**២. តើស្ដេចសាឡូម៉ូនបានសុំអ្វីពីព្រះយេហូវ៉ា?**
គឺប្រាជ្ញា ដើម្បីនឹងគ្រប់គ្រងលើពួកសាសន៍របស់គាត់។
(១ពង្សាវតារក្សត្រ៣:៨-១២)

**៣. តើព្រះយេហូវ៉ាបានផ្ដល់ប្រាជ្ញានោះអោយទៅគាត់ឬទេ?**
មែនហើយ ហើយទ្រង់បានអោយទ្រព្យសម្បត្តិ និងកេរ្តិ៍ឈ្មោះដល់គាត់ទៀតផង។ (១ពង្សាវតារក្សត្រ៣:១៣,៩:២៩-៣០)

**៤. តើនៅពេលណាដែលសាឡូម៉ូនបង្ហាញប្រាជ្ញារបស់គាត់?**
គឺនៅពេលដែលម្ដាយពីរនាក់ដណ្ដើមចង់បានកូនតូចម្នាក់។
(១ពង្សាវតារក្សត្រ៣:១៦-២៨)

**៥. តើស្ដេចសាឡូម៉ូនបានសង់អ្វីឡើង?**
ព្រះវិហារដ៏ធំស្រស់ស្អាតមួយ។ (១ពង្សាវតារក្សត្រ៦:១-១០)


Copyright © Gratia Dei Sola Media

**៦. ហេតុអ្វីបានជាមហាក្សត្រីស្រុកសេបាមកឯសាឡូម៉ូន?**

ដើម្បីនឹងមកមើលសិរីល្អ ដែលព្រះបានប្រទានដល់គាត់។ (១ពង្សាវតារក្សត្រ១០:១,៤-៩)

**៧. តើស្តេចសាឡូម៉ូនបានប្រព្រឹត្តបាបអ្វី?**

ទ្រង់បានយកស្ត្រីសាសន៍ដទៃ ជាច្រើននាក់ធ្វើជាប្រពន្ធ។ (១ពង្សាវតារក្សត្រ១១:១-៤)

**៨. តើពួកប្រពន្ធរបស់គាត់បានជំរុញអោយគាត់ប្រព្រឹត្តបាបកាន់តែច្រើនឡើង ឬទេ?**

មែនហើយ ពួកនាងបានជំរុញអោយគាត់ថ្វាយបង្គំ ពួករូបព្រះក្លែងក្លាយ។ (១ពង្សាវតារក្សត្រ១១:៧-៨)

**៩. តើព្រះបានបង្ហាញដូចម្តេចថាទ្រង់មិនសព្វព្រះទ័យ?**

ព្រះទ្រង់បានដកយករាជ្យពីកូនរបស់គាត់។ (១ពង្សាវតារក្សត្រ១១:៩-១៣)

**១០.តើស្តេចសាឡូម៉ូនបានប្រែចិត្តដោយដឹងពីកំហុសខ្លួនឬទេ?**

គាត់បានប្រែចិត្ត ហើយគាត់បានសរសេរគម្ពីរសាស្តាក្នុងវ័យចំណាស់របស់គាត់ទៀតផង។ (សាស្តា ១២:១៣-១៤)

**ខគម្ពីរចងចាំ៖** "សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជាដើមចមនៃប្រាជ្ញា"។ (សុភាសិត ១:៧)



Copyright © Gratia Dei Sola Media

# មេរៀនទី ៦

## រេហូបោម ស្តេចស្រុកយូដា

## ១ពង្សាវតារក្សត្រ ១២-១៤

**១. តើអ្នកណាបានឡើងសោយរាជ្យបន្ទាប់ពីស្តេចសាឡូម៉ូន?**
កូនរបស់គាត់ រេហូបោម ។(១ពង្សាវតារក្សត្រ១១:៤៣-១២:១)

**២. តើពួករាស្ត្របានស្នើសុំអោយរេហូបោមធ្វើអ្វី?**
ពួករាស្ត្របានសុំអោយទ្រង់បញ្ចុះថ្លៃពន្ធ។
(១ពង្សាវតារក្សត្រ១២:៣-៤)

**៣. តើស្តេចរេហូបោមបានធ្វើតាមសំណូមពររបស់រាស្ត្រឬទេ?**
ទេ! ទ្រង់បានឆ្លើយតបទៅពួកគេ ដោយពាក្យសំដីមិនគួរសម ហើយថែមទាំងតម្លើងថ្លៃពន្ធថែមទៀត។
(១ ពង្សាវតារក្សត្រ១២:១២-១៤)

**៤. តើរាស្ត្របានធ្វើការបះបោរទាស់នឹងស្តេចរេហូបោមដូចម្តេច?**
ពូជអំបូរទាំង១០ បានតាំងយេរ៉ូបោមអោយធ្វើជាស្តេចរបស់ពួកគេ។ (១ពង្សាវតារក្សត្រ១២:២០)

**៥. តើការនេះត្រឹមត្រូវឬទេ ដែលរាស្ត្របានធ្វើបែបនេះ?**
ទេ!ព្រោះព្រះតាំងរេហូបោមអោយធ្វើជាស្តេចរបស់ពួកគេរួចទៅហើយ ។ (១ពង្សាវតារក្សត្រ១២:១,១សាំយូអែល២៤:១០)



Copyright © Gratia Dei Sola Media

**៦. តើពូជអំបូរទាំង១០ត្រូវបានគេហៅដូចម្តេច?**

នគរអ៊ីស្រាអែល ឬនគរខាងជើង ។
(១ពង្សាវតារក្សត្រ១២:១៩-២០)

**៧. តើមានពូជអំបូរប៉ុន្មានដែលនៅជាមួយស្តេចរេហូបោម?**

មានពីរគឺ ពូជពង្សយូដា និងពូជអំបូរបេនយ៉ាមីន។
(១ពង្សាវតារក្សត្រ១២:២១)

**៨. តើពូជអំបូរទាំងពីរនេះត្រូវបានគេហៅដូចម្តេច?**

នគរយូដា ឬនគរខាងត្បូង ។ (១ពង្សាវតារក្សត្រ១២:២៣,២៧)

**៩. តើស្តេចរេហូបោមបំរើព្រះយេហូវ៉ាជារៀងរហូតឬទេ?**

ទេ!ទ្រង់និងរាស្ត្ររបស់ទ្រង់បានដើរចេញពីព្រះជាម្ចាស់។
(១ពង្សាវតារក្សត្រ១៤:២១-២៤)

**១០.តើព្រះយេហូវ៉ាបានធ្វើទោសរេហូបោមដូចម្តេច?**

ព្រះបានបញ្ជូនស្តេចនៃស្រុកអេស៊ីព្ទ មកប្រឆាំងនឹងរេហូបោម
(១ពង្សា វតារក្សត្រ១៤:២៥-២៦)។

**ខគម្ពីរចងចាំ៖** "ឱព្រះយេហូវ៉ាអើយ សូមអោយសេចក្តីសប្បុរសរបស់ទ្រង់សណ្ឋិតនៅលើយើងខ្ញុំ តាមដែលយើងខ្ញុំបានសង្ឃឹមដល់ទ្រង់"។
(ទំនុកដំកើង ៣៣:២២)


Copyright © Gratia Dei Sola Media

# មេរៀនទី ៧
# យេរ៉ូបោម ស្តេចពួកអ៊ីស្រាអែល
## ១ពង្សាវតារក្សត្រ ១២-១៤

**១. តើយេរ៉ូបោមជាស្តេចល្អឬទេ?**
ទេ! ទ្រង់បានអោយពួកអ៊ីស្រាអែលថ្វាយបង្គំកូនគោមាស។
(១ពង្សាវ តារក្សត្រ១២:២៨)

**២. ហេតុអ្វីបានជាយេរ៉ូបោមធ្វើរូបគោមាសទាំងនេះ?**
ព្រោះទ្រង់មិនចង់អោយរាស្ត្ររបស់ទ្រង់ទៅព្រះវិហារ នៅក្រុង
យេរូសាឡិមទេ។ (១ពង្សាវតារក្សត្រ១២:២៦-៣០)

**៣. តើអ្នកណាបាននិយាយទាស់នឹងអាសនៈ ដែលយេរ៉ូបោម
បានស្អាង?**
ហោរាម្នាក់មកពីស្រុកយូដា ។(១ពង្សាវតារក្សត្រ១៣:១-២)

**៤. តើមានអ្វីកើតឡើងនៅពេលដែលហោរានេះ និយាយទាស់នឹង
អាសនា?**
អាសនានោះត្រូវបានរលំហើយបែកជាច្រើនបំណែក។
(១ពង្សាវរតាក្សត្រ១៣:២-៥)

**៥. តើមានអ្វីកើតឡើងចំពោះហោរានេះ ពេលគាត់កំពុងធ្វើដំណើរ
ទៅផ្ទះ?**
មានសត្វតោមួយក្បាលបានហែកសម្លាប់គាត់បង់។
(១ពង្សាវតារក្សត្រ១៣:២៤)


Copyright © Gratia Dei Sola Media

**៦. ហេតុអ្វីបានហោរានេះត្រូវស្លាប់ដោយសារសត្វតោ?**
ព្រោះតែគាត់មិនបានត្រឡប់ទៅស្រុកយូដាវិញភ្លាម ដូចព្រះបង្គាប់ទេ។ (១ពង្សាវតារក្សត្រ១៣:៧-៩,១១-១៩,២៥-២៦)

**៧. ហេតុអ្វីបានជាហោរាម្នាក់នេះមិនធ្វើតាមការបង្គាប់របស់ព្រះ?**
ព្រោះមានមនុស្សម្នាក់បន្លំជាព្រះនិយាយបញ្ឆោតគាត់
មិនអោយត្រឡប់ទៅវិញ ។ (១ពង្សាវតារក្សត្រ១៣:១៨)

**៨. តើព្រះយេហូវ៉ា បានធ្វើទោសដល់យេរ៉ូបោមដូចម្តេចម្រាប់អំពើបាបរបស់គាត់?**
ព្រះយេហូវ៉ាបានធ្វើអោយកូនប្រុសរបស់គាត់មានជំងឺ។
(១ពង្សាវតារក្សត្រ១៣:៣៣-១៤:១)

**៩. តើប្រពន្ធរបស់យេរ៉ូបោម បានព្យាយាមសង្គ្រោះជីវិតកូនប្រុសរបស់នាងយ៉ាងដូចម្តេច ?**
នាងបានទៅឯអ័ហ៊ីយ៉ាដែលជាហោរានៃព្រះ។
(១ពង្សាវតារក្សត្រ១៤:២-៥)

**១០.តើអ័ហ៊ីយ៉ាបានប្រាប់អ្វីដល់ប្រពន្ធរបស់យេរ៉ូបោម?**
កូនរបស់នាងនឹងស្លាប់ជាប្រាកដ។
(១ពង្សាវតារក្សត្រ១៤:៦,១២-១៣)

**ខគម្ពីរចងចាំ៖** "ដ្បិតទ្រង់មិនមែនជាព្រះដែលសព្វព្រះហឫទ័យនឹងសេចក្តីល្មើសទេ"។ (ទំនុកដំកើង ៥:៤)


Copyright © Gratia Dei Sola Media

# មេរៀនទី ៨
# អេលីយ៉ា និង អ័ហាប់
## ១ពង្សាវតារក្សត្រ ១៦-១៧

**១. តើនៅនគរអ៊ីស្រាអែលមានស្តេចល្អៗឬទេ?**
ទេ! ពួកស្តេចទាំងនោះសុទ្ធតែអាក្រក់ទាំងអស់។
(១ពង្សាវតាក្សត្រ ១៦:៣០,៣៣,២ពង្សាវតារក្សត្រ៨:១៨,១៦:៣)

**២. តើស្តេចណាមួយដែលអាក្រក់ជាគេបំផុត?**
គឺស្តេចអ័ហាប់ ដែលបានយកយេសិបិលជាស្ត្រីអាក្រក់ធ្វើជាភរិយា។(១ពង្សាវតារក្សត្រ១៦:៣០-៣១)

**៣. តើស្តេចអ័ហាប់ចង់អោយអ៊ីស្រាអែលគោរពប្រតិបត្តិព្រះឬទេ?**
ទេ! ស្តេចនេះបានអោយរាស្ត្រទាំងនោះ ថ្វាយបង្គំព្រះបាល។ (១ពង្សាវតារក្សត្រ១៦:៣២)

**៤. តើស្តេចអ័ហាប់បានបង្ខំរាស្ត្រទាំងនោះ អោយគោរពប្រតិបត្តិព្រះបាលដូចម្តេច?**
ទ្រង់បានសម្លាប់អស់អ្នកណា ដែលបានគោរពប្រតិបត្តិដល់ព្រះយេហូវ៉ា ។ (១ពង្សាវតារក្សត្រ១៦:៣៣,១៨:៣-៤)

**៥. តើហោរាណាមួយបានមកឯស្តេចអ័ហាប់?**
ហោរា អេលីយ៉ា ។(១ពង្សាវតារក្សត្រ១៧:១)



Copyright © Gratia Dei Sola Media

**៦. តើហោរាអេលីយ៉ាបានប្រាប់អ្វីដល់ស្តេចអ័ហាប់?**

ក្នុងប៉ុន្មានឆ្នាំខាងមុខនេះ នឹងគ្មានភ្លៀង គ្មានទឹកសន្សើម រយៈពេល៣ឆ្នាំកន្លះ។ (១ពង្សាវតារក្សត្រ១៧:១,យ៉ាកុប៥:១៧)

**៧. តើអេលីយ៉ាទៅកន្លែងណាខ្លះ កំឡុងពេលមានអំណាត់អត់?**

គាត់បានទៅលាក់ខ្លួននៅក្បែរជ្រោះកេរីត។ (១ពង្សាវតារក្សត្រ១៧:២-៣)

**៨. តើព្រះយេហូវ៉ាបានចិញ្ចឹមអេលីយ៉ាងដូចម្តេច នៅកន្លែងជ្រោះកេរីតនោះ?**

ព្រះទ្រង់បានបង្គាប់អោយសត្វក្អែកពាំនំប៉័ង និងសាច់មកអោយអេលីយ៉ា។ (១ពង្សាវតារក្សត្រ១៧:៤-៧)

**៩. តើព្រះបញ្ជូនអេលីយ៉ាទៅកន្លែងណាវិញ បន្ទាប់ពីកន្លែងជ្រោះកេរីតរីងទៅ?**

ទៅឯផ្ទះរបស់ស្ត្រីមេម៉ាយក្រម្នាក់ នៅឯក្រុងរបស់ពួកស៊ីដូន។ (១ពង្សាវតារក្សត្រ១៧:៨-១២)

**១០.តើព្រះបានថែរក្សាអេលីយ៉ា និងស្ត្រីមេម៉ាយនោះដូចម្តេច?**

ទ្រង់បានផ្តល់ប្រេង និងអាហារដល់គាត់ទាំងពីរនាក់ជារៀងរាល់ថ្ងៃ។(១ពង្សាវតារក្សត្រ១៧:១៣-១៦)

**ខគម្ពីរចងចាំ៖** "ព្រះនៃខ្ញុំ ទ្រង់នឹងបំពេញគ្រប់ទាំងអស់ដែលអ្នករាល់គ្នាត្រូវការ ក៏តាមភោគសម្បត្តិនៃទ្រង់ដ៏ឧត្តមក្នុងព្រះគ្រីស្ទយេស៊ូវ"។ (ភីលីព ៤:១៩)



Copyright © Gratia Dei Sola Media

# មេរៀនទី ៩
# អេលីយ៉ាលើកំពូលភ្នំកើមែល
## ១ពង្សាវតារក្សត្រ ១៨

**១. តើរហូតដល់ពេលណា ទើបអំណត់អត់ត្រូវបានបញ្ចប់?**
គឺនៅពេលដែលព្រះបានបញ្ជូនហោរាអេលីយ៉ា ទៅឯអ័ហាប់ម្តងទៀត ។(១ពង្សាវតារក្សត្រ១៨:១)

**២. តើអេលីយ៉ាបានប្រាប់ស្តេចអ័ហាប់អោយធ្វើអ្វី?**
អោយនាំពួកអ៊ីស្រាអែលទាំងអស់ទៅឯភ្នំកើមែល។
(១ពង្សាវតារក្សត្រ ១៨:១៧-១៩)

**៣. តើមានអ្នកណាទៀតបានមកឯភ្នំកើមែល ?**
ពួកហោរានៃព្រះបាលចំនួន៤៥០នាក់។
(១ពង្សាវតារក្សត្រ១៨:១៩-២២)

**៤. តើអេលីយ៉ាបានប្រាប់ពួកគេអោយធ្វើអ្វី ?**
ធ្វើអាសនាមួយដល់ព្រះបាល។
(១ពង្សាវតារក្សត្រ១៨:២២-២៤)

**៥. តើពួកហោរាទាំងនោះ អាចដាក់ភ្លើងលើអាសនារបស់ពួកគេបានទេ?**
ទេ! ពួកគេត្រូវសុំការអនុញ្ញាតពីព្រះបាលសិន ទើបអាចធ្វើការនេះបាន។(១ពង្សាវតារក្សត្រ១៨:២៥)


Copyright © Gratia Dei Sola Media

## ៦. តើព្រះបាលអាចបញ្ជូនភ្លើងអោយមកបានទេ?

ទេ! ព្រោះព្រះបាលគ្រាន់តែជារូបព្រះមួយប៉ុណ្ណោះ។
(១ពង្សាវតារក្សត្រ ១៨:២៦-២៩)

## ៧. តើមានអ្វីកើតឡើងបន្ទាប់ពីអេលីយ៉ាបានអធិដ្ឋាន?

ព្រះបានបញ្ជូនភ្លើងចុះមកពីស្ថានសួគ៌ មកលើអាសនារបស់គាត់ ។(១ពង្សាវតារក្សត្រ១៨:៣០-៣៩)

## ៨. តើពួករាស្ត្រពោលដូចម្តេច នៅពេលដែលពួកគេបានឃើញការនេះ?

"ព្រះយេហូវ៉ាទ្រង់ជាព្រះពិតហើយ" ។
(១ពង្សាវតារក្សត្រ ១៨:៣៩)

## ៩. តើអេលីយ៉ាបានធ្វើអ្វីទៅលើពួកហោរារបស់ព្រះបាល?

គាត់បានសម្លាប់ពួកគេទាំងអស់។ (១ពង្សាវតារក្សត្រ១៨:៤០)

## ១០.តើមានអ្វីកើតឡើង បន្ទាប់ពីពួកហោរារបស់ព្រះបាលត្រូវបានសម្លាប់?

ព្រះបង្អុរភ្លៀងចុះមក ដើម្បីឆ្លើយតបសេចក្តីអធិដ្ឋានរបស់អេលីយ៉ា។ (១ពង្សាវតាក្សត្រ១៨:៤១-៤៥)

**ខគម្ពីរចងចាំ៖** "អញនេះជាយេហូវ៉ាគ្មានព្រះណាដ៏ទៃឡើយ ក្រៅពីអញឥតមានព្រះណាទៀតសោះ"។ (អេសាយ ៤៥:៥)


Copyright © Gratia Dei Sola Media

# មេរៀនទី ១០
# យ៉ូសាផាត ស្តេចស្រុកយូដា
## ២របាក្សត្រ ១៧-២០

**១. តើនគរយូដាគោរពប្រតិបត្តិរូបកូនគោមាសឬទេ?**
ទេ! ពួកគេបានថ្វាយបង្គំក្នុងព្រះវិហារនៃក្រុងយេរូសាឡិម។ (២របាក្សត្រ១៧:១-៩)

**២. តើយើងបានដឹងអ្វីខ្លះអំពីពួកស្តេចស្រុកយូដា?**
ពួកទ្រង់ទាំងអស់ គឺជាវង់របស់ស្តេចដាវីឌ។ (២របាក្សត្រ៣២:៣២-៣៣,៣៩:១-៣,យេរេមា១៧:២៥)

**៣. ហេតុអ្វីបានជាព្រះដាក់កូនប្រុសរបស់ដាវីឌលើរាជបល្ល័ង្គ?**
ព្រោះអម្ចាស់ព្រះយេស៊ូវគ្រីស្ទនឹងចាប់កំណើត នៅក្នុងវង្សរបស់ដាវីឌ ។ (ម៉ាថាយ១:១,ម៉ាថាយ៩:២៧)

**៤. តើស្តេចស្រុកយូដាទាំងអស់ គោរពប្រតិបត្តិព្រះយេហូវ៉ាឬទេ?**
មួយចំនួនតូចបានគោរព តែមួយចំនួនធំជាស្តេចអាក្រក់។ (២របាក្សត្រ ២១:៣-៤,៦)

**៥. ចូរអោយឈ្មោះស្តេចម្នាក់ដែលកោតខ្លាចដល់ព្រះយេហូវ៉ា បន្ទាប់ពីស្តេចរេហូបោម?**
យ៉ូសាផាត។(២របាក្សត្រ១៧:១-៦)



Copyright © Gratia Dei Sola Media

**៦. តើស្តេចយ៉ូសាផាតបានធ្វើអ្វីសម្រាប់រាស្ត្រស្រុកយូដា?**
ទ្រង់បានបង្រៀនពួកគេអោយគោរពប្រតិបត្តិដល់ព្រះយេហូវ៉ា ។(២របាក្រត្រ១៧:៧-៩)

**៧. តើស្តេចយ៉ូសាផាតបានប្រព្រឹត្តបាបអ្វី?**
ទ្រង់បានទៅជាមួយនឹងអ័ហាប់ធ្វើចំបាំង។
(២របាក្សត្រ១៨:១-៣,២៨,១៩:២)

**៨. តើមានអ្វីកើតឡើងនៅក្នុងចម្បាំងនេះ?**
ស្តេចអ័ហាប់ត្រូវបានគេសម្លាប់ ។(២របាក្សត្រ១៨:៣៣-៣៤)

**៩. តើព្រះយេហូវ៉ាបានប្រទានពរដល់យ៉ូសាផាតដូចម្តេច?**
ព្រះទ្រង់បានធ្វើអោយគាត់មានទ្រព្យសម្បត្តិជាច្រើន។
(២របាក្សត្រ២០:២៥,១៧:៣-៦)

**១០.តើព្រះបានជួយយ៉ូសាផាតប្រឆាំងនឹងពួកសត្រូវគាត់ឬទេ?**
មែនហើយ ព្រះបានធ្វើអោយពួកសត្រូវរបស់គាត់ខ្លបខ្លាចគាត់ជាខ្លាំង។(២របាក្សត្រ២០:២៩-៣០)

**ខគម្ពីរចងចាំ៖** "ចូរអរព្រះគុណដល់ព្រះយេហូវ៉ាចុះ ដ្បិតសេចក្តីសប្បុរសទ្រង់នៅជាប់អស់កល្បជានិច្ច"។ (របាក្សត្រទី២ ២០:២១)



Copyright © Gratia Dei Sola Media

# មេរៀនទី ១១
# ហោរាអេលីសេ
## ២ពង្សាវតារក្សត្រ ២-៥

**១. តើហោរាអេលីយ៉ាងបានស្លាប់ឬទេ?**
ទេ! ព្រះយេហូវ៉ាបានយកទៅឯនគរស្ថានសួគ៌។
(២ពង្សាវតារក្សត្រ ២:១)

**២. តើព្រះបានយកគាត់ទៅនគរស្ថានឋានសួគ៌ដូចម្ដេច ?**
ដោយរទេះចម្បាំងជាភ្លើងក្នុងខ្យល់កួច។
(២ពង្សាវតារក្សត្រ២:១១)

**៣. តើហោរាណាមួយដែលជំនួសតំណែងអេលីយ៉ា ?**
បាវបំរើរបស់អេលីយ៉ា ឈ្មោះអេលីសេ។
(២ពង្សាវតារក្សត្រ២:៨-៩,១២-១៥)

**៤. តើពួកក្មេងជំទង់ប្រុសៗ បានមើលងាយអេលីសេដូចម្ដេច ?**
ពួកគេបានពោលថា “អាទំពែកអើយ ចូរឡើងទៅចុះ”។
(២ពង្សាវរតាក្សត្រ២:២៣)

**៥. តើព្រះយេហូវ៉ា បានធ្វើទោសពួកក្មេងជំទង់ទាំងនោះដូចម្ដេចសម្រាប់ការនេះ?**
មានខ្លាឃ្មុំពីរក្បាលបានសម្លាប់ពួកគេអស់៤២នាក់ ។
(២ពង្សាវតារក្សត្រ ២:២៤)


Copyright © Gratia Dei Sola Media

**៦. តើអ្នកណាបានមកឯហោរាអេលីសេដើម្បីទទួលការព្យាបាល?**
មេទ័ពណាម៉ាន់ ជាមនុស្សកើតរោគឃ្លង់មកពីស្រុកស៊ីរី ។
(២ពង្សាវតារក្សត្រ៥:១,៩)

**៧. តើណាម៉ាន់ដឹងដំណឹងអំពីអេលីសេបានដូចម្ដេច?**
មាននារីសាសន៍យូដាម្នាក់បានប្រាប់គាត់។
(២ពង្សាវតារក្សត្រ៥:២-៤)

**៨. តើមេទ័ពណាម៉ាន់ត្រូវបានព្យបាលដូចម្ដេច?**
គាត់ស្ដាប់តាមអេលីសេ ហើយទៅមុជទឹកក្នុងទន្លេយ័រដាន់
៧ដង ។ (២ពង្សាវតារក្សត្រ៥:១០-១១,១៣-១៥)

**៩. តើបាវបំរើរបស់អេលីសេបានប្រព្រឹត្តបាបអ្វី?**
គាត់បានយកសួយអាករពីមេទ័ពណាម៉ាន់។
(២ពង្សាវតារក្សត្រ៥:១៥-១៦,២០-២៤)

**១០.តើបាវរបស់អេលីសេត្រូវបានធ្វើទោសដូចម្ដេច?**
គាត់បានក្លាយជាកើតជំងឺឃ្លង់ពេញខ្លួន។
(២ពង្សាវតារក្សត្រ៥:២៥-២៧)

**ខគម្ពីរចងចាំ៖** "តើព្រះយេហូវ៉ាជាព្រះនៃអេលីយ៉ា ទ្រង់គង់នៅឯណា"
(២ពង្សាវតាក្សត្រ ២:១៤) ។


Copyright © Gratia Dei Sola Media

# មេរៀនទី ១២
## អេលីសេសន្យាផ្ដល់ស្បៀងដល់ពួកអ៊ីស្រាអែល
## ២ពង្សាវតារក្សត្រ ៦-៧

**១. ហេតុអ្វីបានជាព្រះបញ្ជូនហោរាអេលីសេ ទៅឯពួកអ៊ីស្រាអែលជាមនុស្សអាក្រក់?**
ព្រោះព្រះនៅមានរាស្ដ្ររបស់ទ្រង់ នៅទីនោះនៅឡើយ។
(២ពង្សាវតារក្សត្រ៦:៨-១០,១ពង្សាវតាក្សត្រ១៩:១៨)

**២. ហេតុអ្វីបានជាស្ដេចស្រុកស៊ីរីព្យាយាមចង់ចាប់អេលីសេ?**
ព្រោះអេលីសេបានជួយស្ដេចសាសន៍អ៊ីស្រាអែល។
(២ពង្សាវតាក្សត្រ ៦:១៣-១៤)

**៣. តើមានអ្វីកើតឡើងចំពោះទ័ពដែលមកចាប់អេលីសេ?**
ព្រះយេហូវ៉ាបានធ្វើអោយពួកគេខ្វាក់ភ្នែក។
(២ពង្សាវតាក្សត្រ៦:១៨)

**៤. តើពួកស៊ីរីបានប្រឆាំងទាស់នឹងសាសន៍អ៊ីស្រាអែល ម្ដងទៀតឬទេ?**
មែនហើយ គឺទ័ពរបស់ពួកគេបានមកឡោមព័ទ្ធកំផែងទីក្រុងសាម៉ារី។ (២ពង្សាវតាក្សត្រ៦:២៤)

**៥. តើការនេះបានបង្ករបញ្ហាដល់ប្រជារាស្ដ្រក្នុងក្រុងដូចម្ដេច?**
ពួកគេបានដាច់ស្បៀងបរិភោគ។ (២ពង្សាវតាក្សត្រ៦:២៥)



Copyright © Gratia Dei Sola Media

**៦. តើពួករាស្ត្រមានការអត់ឃ្លានជាខ្លាំងដែរឬទេ?**

បាទ! ស្ត្រីពីរនាក់សូម្បីតែក្មេងទើបតែកើត ក៏ពួកនាងស៊ីដែរ។ (២ពង្សាវតាក្សត្រ៦:២៦-៣០)

**៧. តើអេលីសេបានសន្យាដូចម្តេច ជាមួយស្តេចអ៊ីស្រាអែល?**

នឹងមានស្បៀងអាហារជាបរិបូរនៅថ្ងៃបន្ទាប់។ (២ពង្សាវតាក្សត្រ៧:១)

**៨. តើស្តេចអង្គនេះបានជឿលើអេលីសេឬទេ?**

ទេ! គឺទ្រង់ និងបាវរបស់ទ្រង់បានចំអក និងមើយងាយលោកអេលីសេ។ (២ពង្សាវតាក្សត្រ៧:២)

៩. តើព្រះបានផ្តល់ស្បៀងអាហារដល់ស្រុកសាម៉ារីដូចម្តេច?

ព្រះបានបណ្តាលអោយពួកស៊ីរីរត់ភៀសខ្លួនចេញអស់ទៅ។ (២ពង្សាវតា ក្សត្រ៧:៥-៧,១៤-១៦)

**១០.តើមានអ្វីកើតឡើងចំពោះបាវម្នាក់ ដែលមើយងាយលោកអេលីសេ?**

គាត់ត្រូវបានគេជាន់ស្លាប់។(២ពង្សាវតាក្សត្រ៧:២,១៧-២០)

**ខគម្ពីរចងចាំ៖** "គឺអញ! អញនេះហើយជាយេហូវ៉ា ក្រៅពីអញ គ្មានអ្នកសង្គ្រោះណាទៀតឡើយ"។ (អេសាយ ៤៣:១១)



Copyright © Gratia Dei Sola Media

# មេរៀនទី ១៣
# យេហ៊ូវ ស្តេចពួកអ៊ីស្រាអែល
## ២ពង្សាវតារក្សត្រ ៩-១០

**១. តើអេលីសេបានបង្គាប់អោយហោរាក្មេងម្នាក់ចាក់ប្រេងតាំងអោយអ្នកណា ឡើងជាស្តេចពួកអ៊ីស្រាអែល?**
គឺជាយេហ៊ូវដែលជាមេទ័ព។(២ពង្សាវតាក្សត្រ៩:២-៣)

**២. តើស្តេចយេហ៊ូវត្រូវបានបង្គាប់អោយធ្វើអ្វី?**
អោយសម្លាប់គ្រួសាររបស់អ័ហាប់ទាំងអស់។
(២ពង្សាវតាក្សត្រ៩:៦-១០)

**៣. តើហេតុអ្វីបានជាព្រះបង្គាប់អោយគាត់ធ្វើការនេះ?**
ព្រោះគ្រួសារទាំងមូលរបស់អ័ហាប់សុទ្ធតែជាមនុស្សអាក្រក់។
(២ពង្សាវតាក្សត្រ៩:៧)

**៤. តើស្តេចយេហ៊ូវបានសម្លាប់អ្នកណាមុនគេ?**
ស្តេចពួកអ៊ីស្រាអែល និងស្តេចស្រុកយូដា។
(២ពង្សាវតាក្សត្រ ៩:២១,២៤,២៧)

**៥. តើព្រះយេហូវ៉ាសព្វព្រះទ័យទេ ដែលយេហ៊ូវបានសំលាប់ស្តេចស្រុកយូដា?**
ទេ! គាត់ត្រូវបានបង្គាប់អោយសំលាប់តែគ្រួសាររបស់អ័ហាប់ប៉ុណ្ណោះ។(ហូសេ១:៤)


Copyright © Gratia Dei Sola Media

**៦. តើស្តេចយេហ៊ូវបានសម្លាប់នាងយេសិបិលដែរឬទេ?**

បាទ\ចាស! ទ្រង់បានប្រាប់ពួកបាវអោយបោះនាងចេញតាមបង្អួច។ (២ពង្សាវតាក្សត្រ៩:៣០-៣៣)

**៧. តើមានអ្វីកើតឡើងចំពោះរាងកាយរបស់នាងយេសិបិល?**

រាងកាយរបស់នាងត្រូវបានសត្វឆ្កែជាច្រើនក្បាលស៊ីអស់។ (២ពង្សាវតារក្សត្រ៩:៣៥-៣៧)

**៨. តើក្រុមគ្រួសាររបស់អ័ហាប់ទាំងអស់ត្រូវបានសម្លាប់ដែរឬទេ?**

មែនហើយ កូនប្រុសរបស់គាត់៧០នាក់ត្រូវបានស្លាប់ដោយកាត់ក្បាល។(២ពង្សាវតាក្សត្រ១០:៦-៨)

**៩. តើស្តេចយេហ៊ូវបានធ្វើពុតជាគោរពប្រតិបត្តិព្រះដូចម្តេច?**

គាត់បានសម្លាប់អស់អ្នកដែលថ្វាយបង្គំព្រះបាល។ (២ពង្សាវតាក្សត្រ ១០:១៨-២៨)

**១០.តើស្តេចយេហ៊ូវពិតជាបានគោរពប្រតិបត្តិព្រះពិតមែនទេ?**

ទេ! គាត់បានធ្វើពួកអ៊ីស្រាអែលគោរពប្រតិបត្តិរូបព្រះម្តងទៀត (២ពង្សាវតាក្សត្រ១០:២៩,៣១)។

**ខគម្ពីរចងចាំ៖** "យញ្ញបូជារបស់មនុស្សអាក្រក់ ជាសេចក្តីស្អប់ខ្ពើមដល់ព្រះយេហូវ៉ា" (សុភាសិត ១៥:៨)



Copyright © Gratia Dei Sola Media

# មេរៀនទី ១៤
# ហោរាយ៉ូណាស
## ព្រះគម្ពីរយ៉ូណាស

**១. តើព្រះយេហូវ៉ាមានព្រះបន្ទូលប្រាប់យ៉ូណាសដូចម្តេច?**
"ចូរទៅទីក្រុងនីនីវេ ជាក្រុងដ៏ធំនោះ ហើយប្រកាសទាស់នឹងក្រុងនោះទៅ"។(យ៉ូណាស ១:២)

**២. តើយ៉ូណាសបានទៅឯក្រុងនីនីវេឬទេ?**
ទេ! គាត់បានរត់គេចខ្លួនចេញទៅឆ្ងាយ។ (យ៉ូណាស១:៣)

**៣. តើមានអ្វីកើតឡើង នៅពេលដែលយ៉ូណាសនៅលើនាវា?**
ព្រះបានបញ្ជូនព្យុះមកលើផ្ទៃសមុទ្រ។(យ៉ូណាស១:៤-៥)

**៤. តើពួកទ័ពលើនាវាបានធ្វើអ្វីទៅលើយ៉ូណាស?**
ពួកគេបានចាប់គាត់បោះទម្លាក់ក្នុងទឹកសមុទ្រ។
(យ៉ូណាស១:៩-១២, ១៥)

**៥. តើយ៉ូណាសបានលង់ទឹកស្លាប់ឬទេ?**
ទេ! ព្រះបម្រុងត្រីធំមួយអោយលេបគាត់ទុកក្នុងពោះ។
(យ៉ូណាស១:១៧,ម៉ាថាយ១២:៤០)

**៦. តើគាត់បានស្លាប់ក្នុងពោះត្រីយ៉ាងធំនោះឬទេ?**
ទេ! បន្ទាប់ពីបីថ្ងៃ ត្រីធំនោះបានខ្ជាក់គាត់ចេញដាក់លើដីគោក។(យ៉ូណាស១:១៧,២:១០)


Copyright © Gratia Dei Sola Media

**៧. តើគ្រាក្រោយមក យ៉ូណាសស្តាប់តាមបង្គាប់របស់ព្រះឬទេ?**
ស្តាប់ គាត់បានចេញទៅក្រុងនីនីវេ ដើម្បីព្រមានដល់ហ្វូង មនុស្សអោយផ្លាស់ប្រែចិត្ត បើមិនដូច្នោះទេព្រះនឹងបំផ្លាញ ពួកគេ។(យ៉ូណាស៣:២-៤)

**៨. តើក្រុងនីនីវេត្រូវបានបំផ្លាញចោលទេ?**
ទេ! ព្រោះមានមនុស្សជាច្រើនអ្នកណាស់បានប្រែចិត្ត។ (យ៉ូណាស ៣:៥, ម៉ាថាយ ១២:៤១)

**៩. តើយ៉ូណាសរីករាយឬទេ ដែលក្រុងនីនីវេត្រូវបានព្រះមេត្តា មិនបំផ្លាញចោល?**
ទេ! គាត់មានចិត្តខឹងជាខ្លាំង។ (យ៉ូណាស៤:១)

**១០.តើព្រះយេហូវ៉ាបានដាស់តឿនយ៉ូណាសអ្វីខ្លះ សម្រាប់ការ ដែលគាត់បានខឹងនោះ?**
នៅមានមនុស្សជាច្រើននាក់ណាស់ដែលមិនទាន់បានស្គាល់ សេចក្តីពិតរបស់ព្រះជាម្ចាស់នៅក្នុងក្រុងនីនីវេ។ (យ៉ូណាស៤:១១)

**ខគម្ពីរចងចាំ៖** "ចៀមខ្ញុំទាំងប៉ុន្មានវាស្គាល់ខ្ញុំហើយមកតាម រីឯខ្ញុំក៏ស្គាល់ វាដែរ"។ (យ៉ូហាន ១០:២៧)


Copyright © Gratia Dei Sola Media

# មេរៀនទី ១៥
# យូអាស ស្តេចស្រុកយូដា
## ២របាក្សត្រ ២២-២៤

**១. តើអ័ថាលាជាអ្នកណា?**
ជាបុត្រីរបស់ស្តេចអ័ហាប់ ជាស្តេចអាក្រក់។
(២របាក្សត្រ២២:១-២,២ពង្សាវតារក្សត្រ៨:១៦-១៨)

**២. តើព្រះនាងអ័ថាលាក្លាយជាម្ចាស់ក្សត្រីបានដូចម្តេច?**
នាងបានសម្លាប់ពួកចៅបង្កើតរបស់នាង។
(២របាក្សត្រ២២:១០)

**៣. តើព្រះអ័ថាលាអាចសម្លាប់ពួកចៅទាំងអស់នោះបានទេ?**
ទេ! ទារកម្នាក់ឈ្មោះយូអាសត្រូវបានគេលាក់ក្នុងព្រះវិហារ។
(២របាក្សត្រ ២២:១១-១២)

**៤. តើយូអាសត្រូវបានតែងតាំងអោយធ្វើជាស្តេចនៅពេលណា?**
នៅពេលដែលយូអាសមានអាយុ៧ឆ្នាំ។
(២របាក្សត្រ២៣:១,២៤:១)

**៥. តើអ្នកណាបានជួយយូអាសអោយបានធ្វើជាស្តេច?**
យេហូយ៉ាដា ជាសង្ឃម្នាក់ដែលគោរពកោតខ្លាចដល់ព្រះ។
(២របាក្សត្រ ២៣:១-៣,១១)

**៦. តើមានអ្វីកើតឡើងចំពោះព្រះនាងអ័ថាលា?**
ព្រះនាងត្រូវបានគេសម្លាប់។(២របាក្សត្រ២៣:២១)



Copyright © Gratia Dei Sola Media

**៧. តើអ្វីៗដែលយូអាសបានធ្វើត្រឹមត្រូវឬទេ?**
មែនហើយ ដរាបណាដែលយេហូយ៉ាដា នៅតែមានជីវិត។
(២របាក្សត្រ២៤:២)

**៨. តើយូអាសបានប្រព្រឹត្តអំពើល្អអ្វី?**
ទ្រង់បានជួសជុលព្រះវិហារឡើងវិញ។
(២របាក្សត្រ២៤:៤-៥,១១-១៤)

**៩. តើយូអាសបានធ្វើអ្វី បន្ទាប់ពីសង្ឃយេហូយ៉ាដាបានស្លាប់ទៅ?**
ទ្រង់បានគោរពប្រតិបត្តិពួករូបព្រះក្លែងក្លាយ។
(២របាក្សត្រ២៤:១៧-១៨)

**១០.តើមានអំពើបាបអ្វីទៀតដែលយ៉ូអាសបានប្រព្រឹត្ត?**
ទ្រង់បានសម្លាប់កូនប្រុសរបស់សង្ឃយេហូយ៉ាដា ដែលជាហោរា ។(២របាក្សត្រ២៤:២០-២២)

**ខគម្ពីរចេងចាំ៖** "អ្នកណាដែលនៅជាប់ក្នុងទីកំបាំង នៃព្រះដ៏ខ្ពស់បំផុត នោះនឹងបានជ្រកនៅក្រោមម្លប់នៃព្រះដ៏មានគ្រប់ព្រះចេស្តា"។
(ទំនុកដំកើង ៩១:១)


Copyright © Gratia Dei Sola Media

# មេរៀនទី ១៦

# ហោសេគា ស្តេចស្រុកយូដា

## ២ពង្សាវតារក្សត្រ ១៦-២០

## និង២របាក្សត្រ ២៩-៣២

**១. ចូរអោយឈ្មោះស្តេចល្អមួយអង្គទៀតរបស់ស្រុកយូដា?**

គឺស្តេច ហោសេគា ជាស្តេចដែលគោរពប្រតិបត្តិដល់ព្រះជាខ្លាំងបំផុតនៅក្នុងស្រុកយូដា។

(២ពង្សាវតាក្សត្រ១៨:១-៧, ២របាក្សត្រ៣២:៣២-៣៣)

**២. តើរាស្ត្រនៅគោរពប្រតិបត្តិព្រះទេ នៅពេលដែលហោសេគាឡើងគ្រងរាជ្យ?**

ទេ! សូម្បីតែទ្វាព្រះវិហារក៏ត្រូវបានបិទទាំងអស់ដែរ។

(២ពង្សាវតារក្សត្រ១៦:៨,១៤,១៨ ២របាក្សត្រ២៨:២៤, ២៩:៦-៧)

**៣. តើស្តេចហោសេគាមានបំណង អោយពួករាស្ត្រគោរពប្រតិបត្តិដល់ព្រះឬទេ?**

មែនហើយ ទ្រង់បានបើកទ្វាព្រះវិហារទាំងអស់។

(២របាក្សត្រ២៩:៣)

**៤. តើស្តេចហោសេគាបានធ្វើអ្វី ចំពោះរូបព្រះក្លែងក្លាយនៃរាស្ត្រទាំងនោះ?**

ទ្រង់បានបំផ្លាញចោលទាំងអស់ ។ (២ពង្សាវតារក្សត្រ១៨:៤)



Copyright © Gratia Dei Sola Media

**៥. តើស្តេចហេសេគាបានបំផ្លាញអស់ទាំងទីខ្ពស់ៗ ដែលបានប្រើសម្រាប់ថ្វាយបង្គំព្រះឬទេ?**

បាទ\ចាស សម្រាប់ព្រះគួរតែត្រូវបានគោរពតាមដែលទ្រង់បានកំណត់អោយ។

(២ពង្សាវតារក្សត្រ១៨:៤,២២,ចោទិយកថា១២:៣២)

**៦. តើស្តេចហេសេគាបានធ្វើយ៉ាងណា ដើម្បីបញ្ជាក់ថាទ្រង់ចង់អោយពួកសាសន៍យូដាគោរពដល់ព្រះ?**

ទ្រង់បានប្រារព្ធពិធីបុណ្យរំលងដ៏ធំមួយ។(២របាក្សត្រ ៣០:១)

**៧. តើស្តេចហេសេគាបានអញ្ជើញតែពួកសាសន៍យូដាអោយចូលរួមក្នុងពិធីបុណ្យនោះប៉ុណ្ណោះមែនទេ?**

ទេ! ទ្រង់ក៏បានអញ្ជើញពួកសាសន៍អ៊ីស្រាអែលខាងជើងដែរ។

(២របាក្សត្រ៣០:១-២)

**៨. តើពួកអ៊ីស្រាអែលបានមកឬទេ បន្ទាប់ពីស្តេចហេសេគាបានអញ្ជើញពួកគេ?**

បាទ\ចាស ជាច្រើននាក់បានមក ប៉ុន្តែមួយចំនួនធំទៀតបានបដិសេធ។ (២របាក្សត្រ៣០:១០-១៣)

**៩. តើមានអ្វីកើតឡើងដល់ពួកសាសន៍អ៊ីស្រាអែល នៅសម័យស្តេចហេសេគា?**

ព្រះបានដាក់ពួកគេអោយធ្វើជាឈ្លើយ ព្រោះអំពើបាបពួកគេ។

(២ពង្សាវតារក្សត្រ១៨:១០-១១,១៧:៥-៦)



Copyright © Gratia Dei Sola Media

**១០.តើសាសន៍អ៊ីស្រាអែល បានវិលត្រឡប់ទៅស្រុកវិញទេ?**

ទេ ពួកគេមួយចំនួនធំមិនបានត្រឡប់ទៅវិញទេ។

(កិច្ចកា២:៥-១១)

**ខគម្ពីរចងចាំ៖** "មានពរហើយ នគរណាដែលយកព្រះយេហូវ៉ាទុកជាព្រះរបស់ខ្លួន គឺជាសាសន៍ដែលទ្រង់បានរើសទុកជាមរដករបស់ទ្រង់" (ទំនុកដំកើង ៣៣:១២)។



Copyright © Gratia Dei Sola Media

# មេរៀនទី ១៧
# ស្តេចហេសេគាមានជំងឺ
## អេសាយ ៣៦-៣៩

**១. តើអ្នកណាបានមកច្បាំងនឹងស្តេចហេសេគា?**
គឺស្តេចស្រុកអាសស៊ើរជាមួយកងទ័ពរបស់ទ្រង់។
(អេសាយ៣៦:១)

**២.តើស្តេចស្រុកអាសស៊ើរបានប្រព្រឹត្តអ្វី?**
ទ្រង់បានបញ្ជូនមនុស្សអោយមកបំបាក់ទឹកចិត្តរាស្រ្ត
បន្ទាប់មកទ្រង់បានបញ្ជូនសារមួយមកឯស្តេចហេសេគា។
(អេសាយ៣៦:៤-៧,១៣-១៨, ៣៧:៨-១៤)

**៣. តើក្នុងសារនោះមានអត្ថន័យដូចម្តេច?**
ព្រះយេហូវ៉ាមិនអាចជួយស្តេចហេសេគាបានទេ។
(អេសាយ៣៧:១០)

**៤. តើស្តេចហេសេគាបានធ្វើអ្វីទៅលើសំបុត្រនោះដូចម្តេច?**
ទ្រង់បានលាសំបុត្រនោះនៅចំពោះមុខព្រះយេហូវ៉ា
ហើយបានអធិស្ឋាន។(អេសាយ៣៧:១៤-១៥)

**៥. តើហោរាអេសាយបានប្រាប់ស្តេចហេសេគាអោយធ្វើអ្វី?**
អោយជឿទុកចិត្តលើព្រះយេហូវ៉ាតែមួយគត់។
(អេសាយ ៣៧:៥-៦, ២ពង្សាវតារក្សត្រ១៩:២០-២១,៣២-៣៤)


Copyright © Gratia Dei Sola Media

**៦. តើព្រះយេហូវ៉ាបានជួយស្តេចហេសេគាដូចម្តេច?**

ទ្រង់បានសម្លាប់ពួកទ័ពរបស់ស្តេចអាសស៊ើរ។
(អេសាយ៣៧:៣៦)

**៧. តើគ្រានោះមានអ្វីកើតឡើងចំពោះស្តេចហេសេគា?**

ទ្រង់បានធ្លាក់ខ្លួនឈឺជាទំងន់ ។(អេសាយ៣៨:១)

**៨. តើស្តេចហេសេគាបានអធិដ្ឋានអ្វីនៅពេលទ្រង់ឈឺ?**

ទ្រង់បានអធិស្ឋានសុំអោយជាពីជំងឺ។
(អេសាយ ៣៨:២-៣)

**៩. តើព្រះយេហូវ៉ាបានឮសេចក្តីអធិដ្ឋានរបស់ទ្រង់ឬទេ?**

បាទ\ចាស ព្រះបានព្យាបាលគាត់អោយជា ហើយបានអោយ
កូនប្រុសម្នាក់ដល់គាត់ថែមទៀតផង។
(អេសាយ៣៨:៤-៥, ២ពង្សាវតាក្សត្រ២០:២១)

**១០.តើបុត្រានោះជានរណា?**

ម៉ានាំសេ។(២ពង្សាវតារក្សត្រ២០:២១-២១:១)

**ខគម្ពីរចងចាំ៖** "ព្រះយេហូវ៉ាទ្រង់ជាពន្លឺ ហើយជាសេចក្តីសង្គ្រោះរបស់ខ្ញុំ
តើខ្ញុំនឹងត្រូវខ្លាចចំពោះអ្នកណា"។ (ទំនុកដំកើង ២៧:១)



Copyright © Gratia Dei Sola Media

# មេរៀនទី ១៨
# ម៉ាន៉ាសេ ស្តេចស្រុកយូដា
## ២របាក្សត្រ ៣៣

១. **តើស្តេចអង្គណាបានឡើងគ្រងរាជ្យបន្ទាប់ពីស្តេចហេសេគា?**
ជាបុត្រារបស់ទ្រង់ឈ្មោះថា ម៉ាន៉ាសេ។ (២របាក្សត្រ៣៣:១)

២. **តើម៉ាន៉ាសេគឺជាស្តេចល្អមួយអង្គឬទេ?**
ទេ! ទ្រង់គឺជាស្តេចដ៏អាក្រក់។(២របាក្សត្រ៣៣:២-៥)

៣. **តើស្តេចម៉ាន៉ាសេបានប្រព្រឹត្តការអាក្រក់អ្វី?**
ទ្រង់បានថ្វាយកូនៗរបស់ទ្រង់ អោយរូបសំណាកព្រះក្លែងក្លាយ។(២របាក្សក្សត្រ៣៣:៦)

៤. **តើម៉ាន៉ាសេបានប្រព្រឹត្តបាបអ្វីទៀតទាស់នឹងព្រះ?**
ទ្រង់បានសម្លាប់ពួករាស្ត្ររបស់ផងព្រះ។
(២ពង្សាវតាក្សត្រ២១:១៦)

៥. **តើព្រះយេហូវ៉ាបានធ្វើទោសស្តេចម៉ាន៉ាសេដូចម្តេច?**
ម៉ាន៉ាសេត្រូវបានជាប់គុកនៅក្រុងបាប៊ីឡូន។
(២របាក្សត្រ៣៣:១១)

៦. **តើព្រះយេហូវ៉ាបានធ្វើអ្វីជាមួយម៉ាន៉ាសេនៅក្នុងគុក?**
ព្រះបានធ្វើអោយម៉ាន៉ាសេមានការសោកស្តាយ
ចំពោះអំពើបាបរបស់ខ្លួន។ (២របាក្សត្រ៣៣:១២)


Copyright © Gratia Dei Sola Media

**៧. តើម៉ាន៉ាសេបាននៅក្នុងគុករហូតឬទេ?**

ទេ! ទ្រង់បានធ្វើជាស្តេចម្តងទៀត។ (២របាក្សត្រ៣៣:១៣)

**៨. តើម៉ាន៉ាសេបានសម្តែងដូចម្តេច ថាទ្រង់សោកស្តាយចំពោះអំពើបាប?**

ទ្រង់បានយកពួករូបសំណាកព្រះក្លែងក្លាយ ចេញពីព្រះវិហារ។ (២របាក្សត្រ៣៣:១៥)

**៩. តើស្តេចម៉ាន៉ាសេបានត្រលប់មកថ្វាយបង្គំព្រះវិញឬទេ?**

មែនហើយ ពួកសម្តេចសង្ឃអាចធ្វើយញ្ញបូជាដល់ព្រះជាថ្មីម្តងទៀត។(២បាក្សត្រ៣៣១៦)

**១០.តើពួករាស្ត្រទាំងនោះបានប្រែចិត្តជាប្រាកដឬទេ?**

ទេ! គួរអោយអាណិត មិនយូរប៉ុន្មានពួកគេក៏បានត្រលប់ទៅរកអំពើបាបរបស់ពួកគេវិញ។(២របាក្សត្រ៣៣:១៧)

**ខគម្ពីរចងចាំ៖** "ឱព្រះយេហូវ៉ាអើយ សូមអត់ទោសការទុច្ចរិតដ៏មានទំងន់របស់ទូលបង្គំផង ដោយយល់ដល់ព្រះនាមទ្រង់"។(ទំនុកដំកើង ២៥:១១)



Copyright © Gratia Dei Sola Media

# មេរៀនទី ១៩
# យ៉ូសៀស ស្តេចស្រុកយូដា
## ២ពង្សាវតារក្សត្រ ២២-២៣

១. **តើស្តេចអង្គណាជាស្តេចល្អក្រោយគេបង្អស់របស់ស្រុកយូដា?**
ស្តេចយ៉ូសៀស។(២របាក្សត្រ២២:១២,២៣:២៥)

២. **តើស្តេចយ៉ូសៀសបង្ហាញយ៉ាងណា ថាទ្រង់កោតខ្លាចចំពោះព្រះយេហូវ៉ា?**
ទ្រង់បានបំផ្លាញរូបសំណាកព្រះក្លែងក្លាយចោលទាំងអស់។
(២ពង្សាវតាក្សត្រ ២៣:៦,២៤, ២របាក្សត្រ ៣៤:៣-៤)

៣. **តើស្តេចយ៉ូសៀសបានជួសជុលព្រះវិហារព្រះយេហូវ៉ាឬទេ?**
បាទ! ទ្រង់បានជួលពួកជាងអោយជួសជុលព្រះវិហារឡើងវិញ។ (២ពង្សាវតាក្សត្រ២២:៣-៦)

៤. **តើសម្តេចសង្ឃហ៊ីលគីយ៉ាបានរកឃើញអ្វីនៅក្នុងព្រះវិហារនោះ?**
ព្រះគម្ពីរក្រឹត្យវិន័យមួយក្បាល។
(២ពង្សាវតាក្សត្រ២២:៨,២របាក្សត្រ ៣៤:១៤-១៥)

៥. **តើស្តេចយ៉ូសៀសបានធ្វើអ្វីជាមួយក្រឹត្យវិន័យនេះ?**
ទ្រង់បានអានគម្ពីរក្រឹត្យវិន័យនេះដល់ពួករាស្ត្ររបស់ទ្រង់។
(២ពង្សាវ តាក្សត្រ២៣:១-២)


Copyright © Gratia Dei Sola Media

**៦. តើស្ដេចយ៉ូសៀសបានបង្គាប់ពួករាស្ត្រអោយធ្វើអ្វី?**

អោយកាន់ពិធីបុណ្យរំលង ។(២ពង្សាវតាក្សត្រ២៣:២១)

**៧. តើពិធីបុណ្យរំលងនេះគឺជាពិធីដ៏ធំមួយដែលពួករាស្ត្រត្រូវកាន់មែនទេ?**

មែន ប៉ុន្តែជាច្រើនឆ្នាំគ្មានអ្នកណាចូលចិត្តបុណ្យរំលងសោះ។ (២ពង្សាវតារក្សត្រ២៣:២២-២៣)

**៨. តើស្ដេចយ៉ូសៀសបានស្លាប់យ៉ាងដូចម្ដេច?**

ទ្រង់បានបាត់បង់ជីវិតនៅក្នុងចម្បាំង។

(២ពង្សាវតាក្សត្រ២៣:២៩-៣០,២របាក្សត្រ៣៥:២០-២៤)

**៩. តើពួករាស្ត្រនៅបន្តគោរពប្រតិបត្តិដល់ព្រះទៀតឬទេ?**

ទេ! ពួកគេបានក្លាយជាមនុស្សអាក្រក់ជាងមុនទៅទៀត។

(២របាក្សត្រ ៣៦:១៤-១៦)

**១០.តើព្រះយេហូវ៉ាបានព្រមានដល់ពួករាស្ត្រទាំងនោះដូចម្ដេច?**

ទ្រង់នឹងធ្វើទោសដល់ពួកយូដា ដូចបានធ្វើលើពួក អ៊ីស្រាអែលដែរ។ (២ពង្សាវតារក្សត្រ២៣:២៦-២៧)

**ខគម្ពីរចងចាំ៖** "ឱ ព្រះបន្ទូលនៃទ្រង់ជាចង្កៀងដល់ជើងទូលបង្គំ ហើយជាពន្លឺបំភ្លឺ ផ្លូវរបស់ទូលបង្គំផង" ។(ទំនុកដំកើង ១១៩:១០៥)



Copyright © Gratia Dei Sola Media

# មេរៀនទី ២០
# ហោរា យេរេមា
## យេរេមា ១,២៥,៣៧-៣៩, និង ៤៣

**១. តើយេរេមាជាអ្នកណា?**
គាត់គឺជាហោរាម្នាក់នៅឯស្រុកយូដា។ (យេរេមា១:១,៤-៥)

**២. តើព្រះបានហៅយេរេមាអោយធ្វើជាហោរានៅពេលណា?**
គឺពេលដែលគាត់នៅជាក្មេងប្រុសតូចនៅឡើយ។ (យេរេមា១:៦-៧)

**៣. តើហោរាយេរេមាបានប្រាប់អ្វីអំពីក្រុងយេរូសាឡិម?**
ក្រុងយេរូសាឡិមនឹងត្រូវបានដុតបំផ្លាញចោលដោយភ្លើង។ (យេរេមា ៣៧:៦-១១)

**៤. តើហោរាយេរេមាប្រាប់ថា នឹងមានអ្វីកើតឡើងលើរាស្ត្រទីនោះ?**
ពួករាស្ត្រទាំងនោះនឹងត្រូវបានយកទៅឯក្រុងបាប៊ីឡូនវិញ។ (យេរេមា ៣៧:១៧,៣៨:២-៣)

**៥. តើស្តេចហើយនិងពួកសម្តេចសង្ឃ ជឿលើសម្តីរបស់យេរេមាឬទេ?**
ទេ! ពួកគេបានខឹងនឹងគាត់ជាខ្លាំង។ (យេរេមា៣៨:៤-៥)

**៦. តើយេរេមាបានរងការឈឺចាប់ដូចម្តេច?**
គាត់ត្រូវបានគេចាប់ដាក់ក្នុងរណ្តៅ។ (យេរេមា៣៨:៦)


Copyright © Gratia Dei Sola Media

### ៧. តើព្រះយេហូវ៉ាបានធ្វើទោសដល់ពួកមនុស្ស ដូចដែលទ្រង់មានបន្ទូលឬទេ?

បាទ! ពួកគេត្រូវបាននាំយកទៅឯក្រុងបាប៊ីឡូន។ (យេរេមា ៣៩:៦-៩)

### ៨. តើហោរាយេរេមាបានទៅជាមួយពួកគេឬទេ ?

ទេ! គាត់និងអ្នកមួយចំនួនទៀត ត្រូវបានគេទុកអោយនៅក្រុងយេរូសាឡិម ។(យេរេមា៣៩:១១-១៤)

### ៩. តើហោរាយេរេមាបានអាស្រ័យនៅក្រុងយេរូសាឡិមឬទេ?

ទេ! ពួករាស្ត្របាននាំយកគាត់ទៅឯស្រុកអេស៊ីព្ទវិញ។ (យេរេមា៤៣:៤-៧)

### ១០.តើយេរេមាសន្យាអ្វី ជាមួយពួករាស្ត្រដែលជាប់ជាឈ្លើយ?

សន្យាថា ៧០ឆ្នាំក្រោយ ព្រះនឹងនាំយកពួកគេត្រឡប់ទៅឯស្រុកកំណើតវិញ។(យេរេមា២៥:១១)

**ខគម្ពីរចងចាំ៖** "គឺនឹកពីសេចក្ដីនេះថា កុំតែមានសេចក្ដីសប្បុរសរបស់ព្រះយេហូវ៉ា នោះយើងបានសូន្យបាត់អស់រលីងទៅ"។ (បរិទេវ ៣:២២)



Copyright © Gratia Dei Sola Media

# មេរៀនទី ២១
# ដានីយ៉ែល និង ពួកមិត្តសម្លាញ់របស់គាត់
## ដានីយ៉ែល ១-៤

**១. តើអ្នកណាទៀតដែលត្រូវបានចាប់យកទៅ ជាមួយពួកយូដា ទៅឯក្រុងបាប៊ីឡូន?**

គឺដានីយ៉ែល និងមិត្តសម្លាញ់របស់គាត់បីនាក់ទៀត។ (ដានីយ៉ែល១:១-៤,៦-៧)

**២. តើដានីយ៉ែល និងមិត្តសម្លាញ់ទាំងបីរបស់គាត់បានក្លាយជាអ្នកណា?**

ពួកគេបានក្លាយជាចៅហ្វាយនៅឯក្រុងបាប៊ីឡូន។ (ដានីយ៉ែល៣:៣០, ២:៤៨-៤៩,៦:១-៣)

**៣. តើព្រះបានសម្តែងដូចម្តេច ថាទ្រង់បានគង់នៅជាមួយពួកគាត់?**

ព្រះទ្រង់បានប្រទានអោយពួកគាត់ មានប្រាជ្ញាឆ្លៀវឆ្លាតនៅក្រុងបាប៊ីឡូន។(ដានីយ៉ែល១:១៧-២០)

**៤. តើដានីយ៉ែលបានបង្ហាញប្រាជ្ញារបស់គាត់ដូចម្តេច?**

គាត់បានស្រាយសុបិនរបស់ស្តេចនេប៊ូក្នេសា។

(ដានីយ៉ែល ២:១,១៩,២៨-២៩,៤៧)

**៥. តើស្តេចនេប៊ូក្នេសាបានសុបិនឃើញអ្វី?**

ឃើញរូបមួយយ៉ាងធំត្រូវបានបំផ្លាញខ្ទេចខ្ទី ដោយសារថ្មមួយដុំ។(ដានីយ៉ែល២:៣១-៣៥)



Copyright © Gratia Dei Sola Media

### ៦. តើសុបិននេះមានសេចក្តីសម្រាយដូចម្តេច?

ព្រះគ្រីស្ទនឹងយាងមកបំផ្លាញអស់ទាំងជាតិសាសន៍ទុច្ចរិតនៅលើផែនដី។ (ដានីយ៉ែល២:៣៥-៤៦,ទំនុកដំកើង២:៩, ទំនុកដំកើង១១០, ១កូរិនថូស ១៥:២៤-២៥, វិវរណៈ:១៧:១២-១៨)

### ៧. តើមិត្តសម្លាញ់ទាំងបីនាក់នោះថ្វាយបង្គំព្រះនៅក្នុងក្រុងបាប៊ីឡូន ឬទេ?

មែនហើយ ពួកគេមិនបានក្រាបថ្វាយបង្គំរូបស្តេចទេ ។ (ដានីយ៉ែល៣:៤-៥,៨-១៨)

### ៨. តើស្តេចបានធ្វើទោសដល់ពួកគាត់ដោយព្រោះការនេះឬទេ?

មែនហើយ គេបោះគាត់ទៅក្នុងគុកភ្លើងដែលកំពុងឆេះយ៉ាងសន្ធៅ។ (ដានីយ៉ែល៣:១៩-២៣)

### ៩. តើពួកគាត់ត្រូវបានភ្លើងឆេះស្លាប់ក្នុងគុកភ្លើងនោះឬទេ?

ទេ! ព្រះបានបញ្ជូនម្នាក់ "ដូចជាបុត្រានៃព្រះ" អោយមកក្នុងគុកភ្លើងជាមួយពួកគាត់។(ដានីយែល៣:២៥)

### ១០.តើស្តេចនេះត្រូវព្រះធ្វើទោសដូចម្តេច ចំពោះអំនួតរបស់គាត់?

ព្រះយេហូវ៉ាបានអោយស្តេចនេះរស់នៅដូចជាសត្វជើងបួន។ (ដានីយ៉ែល៤:២៣-៣៣)

**ខគម្ពីរចងចាំ៖** "នោះព្រះនៃយើងខ្ញុំ ដែលយើងខ្ញុំគោរពប្រតិបត្តិតាម ទ្រង់អាចនឹងជួយអោយយើងខ្ញុំរួចពីគុកភ្លើង ដែលឆេះយ៉ាងសន្ធៅបាន"។ (ដានីយ៉ែល ៣:១៧)



Copyright © Gratia Dei Sola Media

# មេរៀនទី ២២
# ដានីយ៉ែលនៅក្នុងរូងតោ
## ដានីយ៉ែល ៦

**១. តើដានីយ៉ែលអធិដ្ឋានទៅកាន់ព្រះ នៅឯក្រុងបាប៊ីឡូនដែរទេ?**
ពិតមែន គាត់អធិដ្ឋានសម្លឹងទៅក្រុងយេរូសាឡិមបីដងក្នុងមួយថ្ងៃ។(ដានីយ៉ែល៦:១០)

**២. ហេតុអ្វីបានដានីយ៉ែលអធិស្ឋានសម្លឹងទៅក្រុងយេរូសាឡិម?**
ព្រោះក្រុងយេរូសាឡិមតំណាងអោយសេចក្តីស្មោះត្រង់របស់ព្រះ។ (ទំនុកដំកើង៤៨:១-៣,១៣២:១៣,អេសាយ២:២-៣)។

**៣. តើពួកចៅហ្វាយដ៏ទៃទៀតច្រណែននឹងដានីយ៉ែលឬទេ?**
មែនហើយ ពួកគេថែមទាំងចង់សម្លាប់គាត់ទៀតផង។ (ដានីយ៉ែល ៦:៣-៥)

**៤. តើពួកចៅហ្វាយបានព្យាយាមសម្លាប់គាត់ដោយវិធីណា?**
ពួកគេស្នើរអោយស្តេចតាំងច្បាប់យ៉ាងព្រៃផ្សៃមួយទៅលើគាត់។(ដានីយ៉ែល ៦:៦-៧)

**៥. តើច្បាប់អាក្រក់មួយនោះជាសេចក្តីបំរាមអ្វី?**
រាស្ត្រទាំងអស់ត្រូវថ្វាយបង្គំតែស្តេចមួយអង្គគត់ប៉ុណ្ណោះ។ (ដានីយែល ៦:៨-៩)



Copyright © Gratia Dei Sola Media

**៦. តើដានីយ៉ែលបានស្តាប់តាមបង្គាប់របស់ស្តេចឬទេ?**
ទេ! គាត់បានអធិដ្ឋានទៅកាន់ព្រះជាម្ចាស់ដូចពេលមុនទៀត។ (ដានីយ៉ែល៦:១០)

**៧. តើស្តេចបានធ្វើអ្វីលើដានីយ៉ែល សម្រាប់ការបដិសេធថ្វាយបង្គំទ្រង់?**
ស្តេចបានបោះគាត់ចូលទៅក្នុងរូងរបស់ពួកសត្វតោ។ (ដានីយ៉ែល៦:១២-១៧)

**៨. តើពួកសត្វតោទាំងនោះបានស៊ីដានីយ៉ែលឬទេ?**
ទេ! ព្រះបានបិទមាត់សត្វតោទាំងនោះ។ (ដានីយ៉ែល៦:២០-២២)

**៩. តើស្តេចបានដាក់ទោសដល់ពួកចៅហ្វាយអាក្រក់ដូចម្តេច?**
ស្តេចបានបោះពួកគេចូលទៅក្នុងរូងតោ ។ (ដានីយ៉ែល៦:២៤)

**១០.តើហ្វូងសត្វតោបានស៊ីពួកចៅហ្វាយអាក្រក់ទាំងនោះទេ?**
មែនហើយ ពួកគេមិនទាន់ធ្លាក់ដល់បាតរូងផង ក៏ត្រូវតោស៊ីអស់ទៅ។ (ដានីយ៉ែល៦:២៤)

**ខគម្ពីរចងចាំ៖** "តែពេត្រុស និងសាវ័កឯទៀតឆ្លើយឡើងថាត្រូវតែស្តាប់បង្គាប់របស់ព្រះជាជាងមនុស្ស"។ (កិច្ចការ ៥:២៩)



Copyright © Gratia Dei Sola Media

# មេរៀនទី ២៣
# ការវិលត្រឡប់ពីក្រុងបាប៊ីឡូន
## អែសរ៉ា ១-៦

**១. តើពួកសាសន៍យូដាបាន អាស្រ័យនៅក្រុងបាប៊ីឡូនរយៈពេលប៉ុន្មានឆ្នាំ?**
ប្រហែលជា៧០ឆ្នាំ។(ដានីយ៉ែល៩:២)

**២. តើពួកគេបានវិលត្រឡប់ទៅវិញដូចម្ដេច?**
ព្រះយេហូវ៉ាបានប្រាប់អោយស្ដេចស៊ីរូស បញ្ជូនពួកគេត្រឡប់ទៅវិញ។ (អែសរ៉ា ១:១-៤)

**៣. តើមានប៉ុន្មាននាក់បានវិលត្រឡប់ទៅក្រុងយេរូសាឡិមវិញ?**
ប្រហែលជា៥ម៉ឺននាក់។ (អែសរ៉ា ២:៦៤-៦៥)

**៤. តើពួករាស្ដ្របានធ្វើអ្វីតំបូងគេបង្អស់?**
ពួកគេបានសង់អាសនាមួយ ហើយក៏បានថ្វាយបង្គំព្រះនៅទីនោះដែរ។(អែសរ៉ា ៣:១-៣)

**៥. តើពួកមនុស្សទាំងនោះបានធ្វើអ្វី បន្ទាប់ពីបានសង់អាសនារួច?**
ពួកគេបានចាប់ផ្ដើមសង់ព្រះវិហារមួយ។(អែសរ៉ា ៣:៧-៩)

**៦. តើព្រះវិហារនោះសង់បានសំរេចឬទេ?**
បាទ\ចាស រយៈពេលជាង២០ឆ្នាំក្រោយមកព្រះវិហារបានសង់រួចរាល់ ដោយហោរាហាកាយ និងហោរាសាការីបានជំរុញលើកទឹកចិត្តពួកគេ។(អែសរ៉ា ៥:១-២,៦:១៤-១៥)


Copyright © Gratia Dei Sola Media

**៧. តើពួកមនុស្សមានសេចក្ដីអំណរឬទេ ពេលដែលពួកគេមានព្រះវិហារឡើងវិញ?**

ពិតណាស់ ប៉ុន្តែមានអ្នកខ្លះបានយំ។(អែសរ៉ា ៣:១២-១៣)

**៨. តើអ្វីបានជាមានអ្នកខ្លះយំ?**

ព្រោះតែព្រះវិហាររបស់ស្ដេចសាឡូម៉ូនស្អាតជាងឆ្ងាយណាស់ (អែសរ៉ា៣:១២,ហាកាយ២:៣)

**៩. តើអ្នកណាបានមកបង្កបញ្ហាដល់ពួកសាសន៍យូដា?**

ពួកសាសន៍សាម៉ារី ដែលជាពួកមនុស្សអាក្រក់។ (អែសរ៉ា ៩:១-១០)

**១០.តើពួកគេបានមកបង្កបញ្ហាដល់ពួកសាសន៍យូដាដូចម្ដេច?**

ពួកគេបានព្យាយាមបញ្ឈប់ការងារក្នុងព្រះវិហារ។ (អែសរ៉ា ៩:៣-៥)

**ខគម្ពីរចងចាំ៖** "ព្រះយេហូវ៉ាបានធ្វើការយ៉ាងធំសម្រាប់យើងមែន យើងក៏អរណាស់ដែរ"។ (ទំនុកដំកើង ១២៦:៣)



Copyright © Gratia Dei Sola Media

# មេរៀនទី ២៤
# នាងអេសធើរ
## ព្រះគម្ពីរ នាងអេសធើរ

**១. តើបណ្ដាពួកសាសន៍យូដាទាំងអស់ បានវិលត្រឡប់ទៅឯក្រុងយេរូសាឡិមវិញដែរឬទេ?**
ទេ! មានអ្នកខ្លះបានអាស្រ័យនៅក្នុងបាប៊ីឡូន។
(នាងអេសធើរ២:៥-៦, ៣:៦)

**២. ចូរអោយឈ្មោះមនុស្សពីរនាក់ដែលបាននៅ?**
ម៉ាដេកាយ និងនាងអេសធើរ ជាបងប្អូនជីដូនមួយរបស់គាត់។
(នាងអេសធើរ២:៥-៧)

**៣. តើមានអ្វីកើតឡើងចំពោះនាងអេសធើរនៅទីនោះ?**
នាងបានក្លាយជាអគ្គមហេសីរបស់ស្ដេចអ័ហាស៊ូរុស។
(នាងអេសធើរ២:២-៤,៨៩,១៦-១៧)

**៤. តើអ្នកណាជាសេនាបតីនៅក្រោមអំណាចរបស់ស្ដេចនេះ?**
ហាម៉ាន ជាអ្នកដែលស្អប់ម៉ាដេកាយ។
(នាងអេសធើរ៣:១-២,៥)

**៥. តើហាម៉ានមានបំណងធ្វើអ្វី?**
គាត់ចង់សម្លាប់ពួកសាសន៍យូដាទាំងអស់។
(នាងអេសធើរ៣:៦, ៨-១២)



Copyright © Gratia Dei Sola Media

**៦. តើអ្នកណាបានស្តាប់ឮផែនការនេះ?**
ម៉ាដេកាយ ជាអ្នកដែលបានប្រាប់នាងអេសធើរ
តាមរយៈហាថាក់។ (នាងអេសធើរ៤:១-១០)

**៧. តើនាងអេសធើរបានប្រាប់ការនេះអោយស្តេចដឹងឬទេ?**
បាទ\ចាស  នាងបានប្រាប់ស្តេចនៅពេលទ្រង់កំពុងធ្វើពិធីជប់លៀង។ (នាងអេសធើរ៦:១៤-៧:៧)

**៨. តើពួកសាសន៍យូដាទាំងអស់ត្រូវបានគេសម្លាប់ឬទេ?**
ទេ! ស្តេចបានបង្គាប់ពួកគេអោយច្បាំងវិញ ដើម្បីអោយមានជីវិតរស់នៅ។ (នាងអេសធើរ៨:៧-១១)

**៩. តើមានអ្វីកើតឡើងចំពោះហាម៉ាន?**
គាត់ត្រូវបានគេព្យួរលើនៅឈើ ដែលគាត់បានដំឡើងសម្រាប់ម៉ាដេកាយ។ (នាងអេសធើរ៧:៩-១០)

**១០.តើការនេះមានន័យសេចក្តីដូចម្តេច?**
ព្រះទ្រង់តែងតែថែរក្សារាស្ត្ររបស់ទ្រង់ជានិច្ច។
(នាងអេសធើរ៨:១, ១៥-១៧,៩:១-៥,យេរេមា២៤:៦-៧)

**ខគម្ពីរចងចាំះ** "ឯសេចក្តីជំនួយរបស់យើង គឺដោយពឹងដល់ព្រះនាមព្រះយេហូវ៉ាដែលទ្រង់បានបង្កើតផ្ទៃមេឃ និងផែនដី"។
(ទំនុកដំកើង១២៤:៨)


Copyright © Gratia Dei Sola Media

# មេរៀនទី ២៥
# នេហេមា
## ព្រះគម្ពីរ នេហេមា

**១. តើនេហេមាជាអ្នកណា?**
ជាអ្នកថ្វាយពែងដល់ស្តេចសាសន៍ពើស៊ី។ (នេហេមា១:១,១១)

**២. តើនេហេមាបានដឹងរឿងអ្វីអំពីពួកសាសន៍យូដា?**
ពួកគេមិនបានកំពុងសាងសង់កំផែងក្រុងយេរូសាឡិមទេ។ (នេហេមា ១:១-៣)

**៣. តើនេហេមាបានធ្វើអ្វីនៅពេលដែលគាត់បានដឹងរឿងនេះ?**
គាត់បានសុំការអនុញ្ញាតពីស្តេច ដើម្បីទៅក្រុងយេរូសាឡិម។ (នេហេមា២:១-៥)

**៤. តើការងារទីមួយរបស់នេហេមាធ្វើនៅក្រុងយេរូសាឡិមគឺអ្វី?**
នៅពេលយប់ គាត់បានសម្លឹងមើលទៅកំផែងក្រុង។ (នេហេមា២:១២-១៣)

៥. តើនេហេមាបានចាប់ផ្តើមសង់កំផែងក្រុងឬទេ?
ពិតមែន គាត់បានរៀបចំពួករាស្ត្រអោយធ្វើ។ (នេហេមា២:១៧-១៨, ៣:១-៣២,៤:៦)

**៦. តើពួករាស្ត្រទាំងនោះបានជួបបញ្ហាដូចម្តេចខ្លះ?**
ពួកមនុស្សអាក្រក់មួយក្រុមបានព្យាយាមបញ្ឈប់ការងាររបស់ពួកគេ។ (នេហេមា២:១៩,៤:១-៣,៧-៨)


Copyright © Gratia Dei Sola Media

**៧. តើពួកគេបានឈប់ធ្វើការសាងសង់ឬទេ?**

ទេ! នេហេមាបានអោយដាវទៅពួករាស្ត្រទាំងនោះ។
(នេហេមា៤:១៣-១៨)

**៨. តើពួកមនុស្សអាក្រក់ទាំងនោះ នៅមករំខានពួករាស្ត្រទៀតទេ?**

មែនហើយ ពួកគេបាននិយាយកុហកអំពីនេហេមា។
(នេហេមា៦:៥-៨,១២-១៤)

**៩. តើរាស្ត្រចំណាយពេលប៉ុន្មានថ្ងៃ ដើម្បីសង់កំផែងឡើងវិញ?**

ចំនួន៥២ថ្ងៃ។ (នេហេមា៦:១៥)

**១០.ហេតុអ្វីបានជាកំផែងក្រុងនេះសង់បានលឿនយ៉ាងនេះ?**

ព្រោះព្រះបានជួយពួករាស្ត្ររបស់ទ្រង់។
(នេហេមា២:១៩-២០,៤:១៦-២៣,អែសរ៉ា៩:៨-៩)

**ខគម្ពីរចងចាំ៖**"ឱព្រះយេហូវ៉ានៃពួកពលបរិវារអើយ មនុស្សណាដែលទុកចិត្តនឹងទ្រង់នោះមានពរហើយ"។(ទំនុកដំកើង ៨៤:១២)



Copyright © Gratia Dei Sola Media